# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១៧

## ជប៉ុនផ្តល់ថវិកាសរុបចំនួន ១៦០,៨០០ ដុល្លារអាមេរិក សម្រាប់ការពង្រឹងសហគមន៍កសិកម្ម និងការលើកកម្ពស់ទឹកស្អាត

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុន បានយល់ព្រមផ្តល់ថវិកាសរុបចំនួន **១៦០,៨០០ដុល្លារអាមេរិក** ដល់អង្គភាពទទួលជំនួយចំនួន២។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំង២សម្រាប់គម្រោងដូចតទៅ៖

**១. <u>គម្រោងពង្រឹងសហគមន៍កសិកម្មក្នុងស្រុកត្បែងមានជ័យ និងស្រុកគូលែន ខេត្តព្រះវិហារ )ថវិកាចំនួន៨២,៩៦០ ដុល្លារអាមេរិក(</u>**

<u>អង្គភាពទទួលជំនួយ៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ</u>

គម្រោងនេះ នឹងផ្តល់ជូននូវម៉ាស៊ីនច្រូតស្រូវចំនួន២ និងអគារមជ្ឈមណ្ឌលសហគមន៍កសិកម្មចំនួន២ ដល់សហគមន៍កសិកម្មទាំងពីរ។ គម្រោងនេះត្រូវបានរំពឹងថា ប្រជាកសិករដែលរស់នៅក្នុងតំបន់ប្រមាណជា ៤៦០នាក់ នឹងទទួលបានអត្ថប្រយោជន៍ពីការលើកកម្ពស់គុណភាពអង្ករសរីរាង្គរបស់ពួកគេ។

**២. <u>គម្រោងសាងសង់ស្ថានីយផលិតទឹកស្អាតខ្នាតតូច នៅក្នុងឃុំចំនួន៦ ខេត្តតាកែវ (ថវិកាចំនួន ៧៧,៨៤០ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយ៖ ទឹកស្អាត១០០១</u>

គម្រោងនេះ នឹងផ្តល់ជូននូវស្ថានីយផលិតទឹកស្អាតខ្នាតតូចចំនួន៦កន្លែង និងម៉ាស៊ីនចាំបាច់សម្រាប់ផលិតទឹកស្អាត នៅក្នុងឃុំចំនួន៦ ខេត្តតាកែវ ដែលក្នុងនោះរួមមាន៖ ឃុំកំពង់រាប ឃុំពន្លៃ ឃុំស្រង៉ែ ឃុំស្រែរនោង ឃុំត្រពាំងធំខាងត្បូង និងឃុំអូរសារាយ។ គម្រោងនេះ ត្រូវបានរំពឹងថា ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ប្រមាណជា ១,៩០០ គ្រួសារ នឹងទទួលបានទឹកស្អាតប្រកបដោយសុវត្ថិភាព និងកាត់បន្ថយនូវអនុបាតនៃជម្ងឺដែលឆ្លងតាមទឹកមិនស្អាត ។

*ជំនួយឥតសំណងគូសាណូណេរបស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសល ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួន

ឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥៦លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន៥៦៧ គម្រោងនៅទូទាំងប្រទេសកម្ពុជា៕

---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*

*ហ្វេសប៊ុក: https://www.facebook.com/JapanEmbassyCambodia/*